**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ:...០៧...ស.ស.ង.៣៨

# សារលិខិតជូនពរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**

នៅក្នុងឱកាសដ៏មង្គលាភិរម្យថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥ និងទី១៦ ខែមេសាខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃទីស្តីការគណៈរដ្ឋមន្ត្រី ខ្ញុំ និងភរិយា សូមសម្តែងនូវសេចក្តីអំណរសាទរឥតឧបមា ប្រកបដោយកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត និងសូមចូលរួមជូននូវសព្ទសាធុការពរជ័យ បវរសួស្តីសិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់យ៉ាងចំពោះសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត សូមបានប្រកបដោយកាយពលមាំមួនខ្លាំងក្លា សុខភាពល្អបរិបូណ៌ បញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ជន្មាយុយឺនយូរ និងមានពលានុភាព កាន់តែខ្លាំងក្លាទ្វេថែមទៀត ក្នុងការដឹកនាំអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ឱ្យទទួលបាននូវជោគជ័យត្រចះត្រចង់ថ្មីៗធំធេងថែមទៀតជូនជាតិមាតុភូមិ និងប្រជាជន។

ខ្ញុំ និងភរិយា រួមទាំងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃទីស្តីការគណៈរដ្ឋមន្ត្រី តែងតែចងចាំជានិច្ចគ្រប់ពេលវេលាមិនអាចបំភ្លេចបាន និងសូមចារិកទុកនៅក្នុងផ្នត់គំនិតនូវកិច្ចខិតខំប្រឹងប្រែងដោយយកអស់កម្លាំងកាយចិត្តប្រាជ្ញាស្មារតី បទពិសោធន៍ប្រកបដោយគតិបណ្ឌិត និងទេពកោសល្យដ៏អស្ចារ្យមកបម្រើឧត្តមប្រយោជន៍ជាតិមាតុភូមិ និងប្រជាជនដែលធ្វើឱ្យមាតុភូមិអង្គរជាទីស្នេហានៃយើងទាំងអស់គ្នាទទួលបាននូវសុខសន្តិភាពពេញលេញ ឯកភាពទឹកដី ស្ថិរភាពនយោបាយសន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ ដែលជាមូលដ្ឋានគ្រឹះក្នុងការស្តារ ការអភិវឌ្ឍ និងការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យប្រកបដោយភាពស៊ីសង្វាក់គ្នា ដែលមានអភិបាលកិច្ចល្អជាស្នូលដ៏រឹងមាំ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពការងារ ការកាត់បន្ថយភាពក្រីក្រ ដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនគ្រប់ៗរូប។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលប្រពៃថ្លៃថ្លានេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ឫទ្ធិបារមីខ្លាំងក្លា ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ព្រះឥន្ទ ព្រះព្រហ្ម បុណ្យបារមីដែលថែរក្សាប្រាង្គប្រាសាទអង្គរ ព្រះអង្គចេក ព្រះអង្គចម ពិសេសទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ព្រះនាម **កិមិរាទេវី** សូមព្រះអង្គតាមជួយថែរក្សាការពារប្រោះព្រំជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត បុត្រា បុត្រី បុត្រប្រសារ និងចៅប្រុស ចៅស្រី ជាទីស្រឡាញ់ និងសូមបានសមប្រកបទៅដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត មេត្តាទទួលនូវអភិវន្ទនាការ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុតអំពីខ្ញុំ និងភរិយា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី** ៧

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**ប៊ិន ឈិន**